ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង

អំពើជួញដូរមនុស្ស

លេខ: ០៧៧/២៥ គ.ជ.ក

# របាយការណ៍

## ស្តីពី

## ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមីនា និងទិសដៅខែមេសា ឆ្នាំ២០២៥

### I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសាកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងសង្គ្រាមប្រដាប់អាវុធដ៏រ៉ាំរ៉ៃ ដែលជំរុញឱ្យមនុស្សរាប់រយលាននាក់បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាលំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង ដែលប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន និងការកេងប្រវ័ញ្ចជាច្រើនរូបភាព។

ការផ្សព្វផ្សាយយ៉ាងទូលំទូលាយរបស់បណ្តាញសារព័ត៌មាននានា ទាំងពិត ទាំងមិនពិត អំពីបទល្មើសជួញដូរមនុស្សនៅកម្ពុជា ព្រមទាំងការចាទប្រកាន់ពីបណ្តាប្រទេស ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលនាំឱ្យមានភាពរាំងស្ទះដល់ដំណើរការនៃចរន្តសេដ្ឋកិច្ចជាតិ និងប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានាក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុស ក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ ចំនួនដ៏ច្រើនលើសលប់នៃប្រជាជនពេញវ័យការងារបានធ្វើចំណាកស្រុក មានរហូតដល់ជាងមួយលាននាក់ បាននិងកំពុងនៅធ្វើការងាររហូតដល់ប្រមាណ ១.៦លាននាក់ នៅក្រៅប្រទេស ដែលស្មើនឹងជិត២០ភាគរយ នៃប្រជាពលរដ្ឋវ័យ ពី១៥ឆ្នាំ ទៅ ៦០ឆ្នាំ និងអត្រាដ៏ខ្ពស់នៃការបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា បានប៉ះពាល់ទៅនឹងកង្វះធនធានពលកម្ម សម្រាប់ទទួលយកការងារដែលត្រូវបានបង្កើតឡើងក្នុងស្រុក តាមរយៈការវិនិយោគលើវិស័យឧស្សាហកម្ម និងសហគ្រាសធំៗ ដែលរាជរដ្ឋាភិបាលបាននិងកំពុងទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបកាន់តែមានប្រសិទ្ធភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ។

នៅក្នុងខែមីនានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី-ខេត្ត ក្នុងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត ដោយមានការចូលរួមគាំទ្រ និងសហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម តាមយុទ្ធសាស្ត្រទាំងបួន នៃផែនការយុទ្ធសាស្ត្រជាតិ ដោយប្រឈមនឹងស្ថានភាពប្រែប្រួលឥតឈប់ឈរនៃបទល្មើស។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ (គ្មាន)

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ២០.១៨៥លើក មានអ្នកចូលរួមសរុបចំនួន ៩០២.៧៣៣នាក់ ក្នុងនោះស្ត្រី ៤៩១.៥៦៣នាក់ (ធៀបនឹងខែកុម្ភៈ មានចំនួន ៧៧២.៦១៤នាក់) គឺមានការកើនឡើងចំនួន ១៣០.១១៩នាក់ ស្មើនឹង១៦,៨៤% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ០១ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ១៩.៥៥៦លើក | ៨៦៨.៦៧៧នាក់ | ៤៧៨.៦៥៦នាក់ |
| ០២ | កម្មវិធីផ្សេងៗ | ៦២៩លើក | ៣៤.០៥៦នាក់ | ១២.៩០៧នាក់ |
| សរុប | | ២០.១៨៥លើក | ៩០២.៧៣៣នាក់ | ៤៩១.៥៦៣នាក់ |
| *(<u>សម្គាល់</u>៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្ដាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)* | | | | |

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ១២២ | ២៧.៧១៩ | ១៣.៣៤០ | ៤១ | ២.២៩៧ | ១.១៨០ |
| ២ | កណ្ដាល | ៣៥៣ | ៦.៥២៦ | ៣.៩៤៩ | ១១៨ | ២.៩៩១ | ១.៥៥៦ |
| ៣ | បាត់ដំបង | ៣.០២០ | ១៦១.៦៣១ | ៨៩.៦៣៧ | ២.១៣៨ | ៧២.៤៤២ | ៣៩.៦៣៣ |
| ៤ | ពោធិ៍សាត់ | ៤៧០ | ៤១.០២៦ | ២២.១២៥ | ២៧៥ | ១០.៣៤៣ | ៥.៤៩៦ |
| ៥ | សៀមរាប | ៦៨៦ | ៣៨.៣១៩ | ២៥.៦៨៣ | ៥៣៩ | ២២.៧១៥ | ១៤.០៧២ |
| ៦ | កំពង់ឆ្នាំង | ៧៨៧ | ២៨.០១២ | ១៥.៤៤៦ | ៣៧៣ | ១៥.១៧៨ | ៨.៤៦៦ |
| ៧ | កំពង់ចាម | ១.៦៧០ | ៩៥៣០៥ | ៤៨.៩៥៩ | ០៤ | ៣២៣ | ១៨៧ |
| ៨ | ព្រះសីហនុ | ១៤៦ | ៤១៩៩ | ២.១៦៦ | ៤៨ | ១.៦៦២ | ៩០០ |
| ៩ | ព្រះវិហារ | ២០ | ៣៤០៨ | ១.៩១៣ | | | |
| ១០ | ស្វាយរៀង | ៣២៤ | ១៩.៤៣១ | ១០.៨៩៤ | ៤៣៧ | ១៦.៦៣៥ | ៩.៦៦២ |
| ១១ | ប៉ៃលិន | ០៣ | ២.៨៤៤ | ១.៥៤៤ | ៩៩ | ៣.៣៦៧ | ១.៥៧៥ |
| ១២ | កោះកុង | ៧០៥ | ១២.៩៦៥ | ៧.១៣០ | ២៥៧ | ៤.២៤៧ | ២.១៥៣ |
| ១៣ | កំពត | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ១៤ | កំពង់ធំ | ៥១៦ | ២៨.៧៣០ | ១៨.៥៤១ | ២៨៧ | ៨.០២៤ | ៤.៣១២ |
| ១៥ | តាកែវ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ១៦ | ក្រចេះ | ៥៦ | ១១២០ | ៧១០ | | | |
| ១៧ | កែប | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ១៨ | កំពង់ស្ពឺ | ២៦៥ | ២៣.៥៩៧ | ១២.១៣៦ | ២៩ | ៩.២១០ | ៤.៩៨៤ |
| ១៩ | ស្ទឹងត្រែង | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២០ | រតនគិរី | ៥១០ | ២៥.៤៩៦ | ១១.៥១៩ | ២១០ | ១០.១៧២ | ៤.៧០២ |
| ២១ | ព្រៃវែង | ១.០៧៨ | ៦៨.៩៨៨ | ៣៨.៦៨២ | ៨៣៤ | ៣១.៧៩៨ | ១៧.៦៦០ |
| ២២ | ត្បូងឃ្មុំ | ៥៣ | ៣.៩៨៧ | ១.៩៧៤ | ១៦៥ | ៤.៨៨៣ | ២.៣៦៤ |
| ២៣ | បន្ទាយមានជ័យ | ១.០៣៦ | ១៦.៤៥៤ | ៩.៦៥៩ | ១.៣៩៩ | ២៦.៤១៩ | ១៥.៣៩៨ |
| ២៤ | ឧត្តរមានជ័យ | ១២៤ | ៦.៤០០ | ៣.៦៣០ | ១០ | ៥៦០ | ៣២២ |
| ២៥ | មណ្ឌលគិរី | ៣២៥ | ៨.៣៣៤ | ៣.៩០៣ | ២៤ | ៩២០ | ៤៩៤ |
| សរុប រាជធានី-ខេត្ត | | ១២.២៦៩លើក | ៦២៤.៤៩១នាក់ | ៣៤៣.៥៤០នាក់ | ៧.២៨៧លើក | ២៤៤.១៨៦នាក់ | ១៣៥.១១៦នាក់ |
| សរុបរួម | | ១៩.៥៥៦លើក | | ៨៦៨.៦៧៧នាក់ | | ៤៧៨.៦៥៦នាក់ | |

❖ **ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ**

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) សហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បានបញ្ជ្រាបការផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈកម្មពិធីផ្សព្វផ្សាយរបាយការណ៍ជាតិឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ កម្មវិធីទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៤ ឆ្នាំ២០២៥ តាមសាលារៀនពេលគោរពទង់ជាតិមុនចូលរៀន និងតាមរយៈកម្មវិធីផ្សេងៗ សរុបចំនួន **៦២៩លើក** មនុស្សចំនួន **៣៤.០៥៦នាក់** ក្នុងនោះស្ត្រី ១៣.០៣៣នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០១ | ៥២០ | ១២៦ |
| ២ | ខេត្តកណ្តាល | ៣៦៣ | ១៧៤៧១ | ៣៨២៤ |
| ៣ | ខេត្តប៉ៃលិន | ០២ | ១២៨ | ៦៥ |
| ៤ | ខេត្តសៀមរាប | ៥១ | ៤៨២៨ | ២៨៣៣ |
| ៥ | ខេត្តកំពង់ឆ្នាំង | ៦៩ | ១៦៤៣ | ៨៦៧ |
| ៦ | ខេត្តកំពង់ចាម | ០៤ | ៣២៣ | ១៨៧ |
| ៧ | ខេត្តត្បូងឃ្មុំ | ០៦ | ២១៨០ | ៧៧៩ |
| ៨ | ខេត្តកំពត | ០១ | ២០០ | ១៩២ |
| ៩ | ខេត្តឧត្តរមានជ័យ | ១១០ | ៣៧៤៩ | ២៣៨៨ |
| ១០ | ខេត្តក្រចេះ | ០៤ | ១៤១៦ | ៨០៣ |
| ១១ | ខេត្តបន្ទាយមានជ័យ | ០៣ | ១៥៤ | ៩២ |
| ១២ | ខេត្តកំពង់ធំ | ១៤ | ១៣៨៣ | ៨៤១ |
| ១៣ | ខេត្តមណ្ឌលគិរី | ០១ | ៦១ | ៣៦ |
| ១៤ | អង្គការ Friend Insertional (សៀមរាប) | ៦១ | ៨៦៦ | ៣២២ |
| ១៥ | អង្គការសាម៉ារីតាន់ភឺស(បាត់ដំបង) | ០៥ | ១០៧៣ | ៦៤៤ |
| | សរុប | ៦២៩លើក | ៣៤.០៥៦នាក់ | ១៣.០៣៣នាក់ |

## ខ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ **ការផលិត និងចែកផ្សាយសម្ភារផ្តល់ព័ត៌មាន និងអប់រំ** (IEC = Information Education Communication Materials)

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | សកម្មភាព និង ឧបករណ៍ផ្សព្វផ្សាយ | ចំនួន លើក | ចំនួន ឧបករណ៍ | ចំនួនអ្នក ទទួលបាន | ចំនួន ស្ត្រី |
|---|---|---|---|---|---|---|
| ១ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១៦.០៣១សន្លឹក | ៤.៥០០នាក់ | ២.០០០នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | បាត់ដំបង | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ៣.០៥៦សន្លឹក | ១.០១៣នាក់ | ៥៦២នាក់ |
| ៣ | បន្ទាយមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | | ១.៦៧៤នាក់ | ៧០៦នាក់ |
| ៤ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ១៦លើក | ១៦សន្លឹក | ៤៤៥នាក់ | ១១២នាក់ |
| ៥ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ៩៦០សន្លឹក | | |
| សរុប | | | ១៦លើក | ១៩.១០៣សន្លឹក | ៧.៦៣២នាក់ | ៣.៣៨០ នាក់ |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក/ដង/ស្ពត | ចំនួនអ្នកទស្សនា/ស្តាប់/អាន/Views |
|---|---|---|---|---|
| ១ | ខេត្តសៀមរាប | -ចាក់ផ្សាយវីដេអូអប់រំខ្លី ស្តីពីការធ្វើទេសន្តប្រវេសន៍ដោយសុវត្ថិភាព និងស្របច្បាប់ ដល់សហគមន៍ និងទីប្រជុំជន<br>-វិទ្យុជាតិ | ០២លើក<br>២១០លើក | |
| ២ | ខេត្តកំពង់ចាម | -វិទ្យុក្នុងកម្មវិធីសន្ទនាមតិ ស្តីពីដំណើរការអនុវត្តន៍គោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ទប់ស្កាត់អំពើជួញដូរមនុស្ស បង្ការ និងទប់ស្កាត់ពលកម្មកុមារខុសច្បាប់ និងការធ្វើចំណាកស្រុកដោយស្របច្បាប់។<br>-បានចាក់ស្ប៉ត អប់រំខ្លីៗ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ០៥ដង ក្នុងមួយថ្ងៃ។ | ០៨លើក<br>១៥០លើក | ២៣(ស្រី១៤) |
| ៣ | ខេត្តប៉ៃលិន | -វិទ្យុជាតិ | ៤៩៦លើក | |
| ៤ | ខេត្តកំពង់ចាម | -វិទ្យុជាតិ | ១៥០លើក | |
| ៥ | ខេត្តត្បូងឃ្មុំ | -វិទ្យុជាតិ | ៣២លើក | |
| ៦ | ខេត្តបន្ទាយមានជ័យ | -វិទ្យុជាតិ | ០៨លើក | |
| សរុប | | | ៩៥៦លើក | ២៣(ស្រី១៤)នាក់ |

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍**

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញផ្តល់កិច្ចសម្ភាសន៍ ជូនអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន ក្រោមប្រធានបទ "សារអប់រំសម្រាប់ស្ត្រី និងក្មេងស្រី ដើម្បីការពារខ្លួនពីអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងការរំលោភបំពានថ្មីគ្រប់ទម្រង់" នាឱកាសអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី ១១៤ ឆ្នាំ២០២៥។

### ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

#### ខ.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ សរុបចំនួន ១៣០នាក់(ស្រី ០៥នាក់) មាន ០៩សញ្ជាតិ និងបានវាយតម្លៃបញ្ជូនឯកសារឱ្យក្រុមការងារប្រចាំច្រកចេញ-ចូលតែមួយ ក្រសួងមហាផ្ទៃចំនួន ៩៥នាក់(ស្រី ០៨នាក់) ។

| បរិយាយ | ចំនួនមនុស្ស | សញ្ជាតិ |
| --- | --- | --- |
| ស្រីបរទេសជាមួយបុរសខ្មែរ | ០៥នាក់ | ចិន៦៩នាក់ កូរ៉េខាងត្បូង២៨នាក់(ស្រី០១នាក់) អាម៉េរិក២០នាក់(ស្រី០៤នាក់) បារាំង០៤នាក់ ម៉ាឡេស៊ី០៣នាក់ កាណាដា០២នាក់ ប៉ាគីស្ថាន០២នាក់ អូស្ត្រាលី០១នាក់ និងហ្វីលីពីន០១នាក់។ |
| បុរសបរទេសជាមួយស្រីខ្មែរ | ១២៥នាក់ | |
| សរុប | ១៣០ នាក់ | ០៩ សញ្ជាតិ |

❖ **ការផ្សព្វផ្សាយ**

▪ ខេត្តកំពង់ចាម៖ រដ្ឋបាលក្រុង បានផ្សព្វផ្សាយអនុក្រឹត្យ ស្ដីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ដល់ប្រជាពលរដ្ឋក្នុងក្រុង សរុបចំនួន **៦២**លើក អ្នកចូលរួមចំនួន ៣.៦៩១នាក់(ស្រី ១.៩០៥នាក់)។

**ខ.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស**

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

អគ្គស្នងការដ្ឋាននគរបាលជាតិ បានតាមដាន និងធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងត្រឡប់មកវិញ តាមរយៈការប្រមូលទិន្នន័យពីបណ្ដាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងប្រទេស ដូចមានក្នុងតារាងខាងក្រោម៖

| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស | | | |
| --- | --- | --- | --- | --- |
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| មីនា | ១៤១.៧២៤នាក់ | ៦៤.១៩៣នាក់ | ៤.៥៦៦នាក់ | ១.៤៣២នាក់ |
| ប្រចាំខែ | ទិន្នន័យពលរដ្ឋខ្មែរដែលវិលត្រឡប់ពីក្រៅប្រទេស | | | |
| | សរុប | ស្រី | អនីតិជន | |
| | | | សរុប | ស្រី |
| មីនា | ១៤.៧៤៣នាក់ | ៦.១១៤នាក់ | ២១៧នាក់ | ៨៣នាក់ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

➕ ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន

| ល.រ | រាជធានី-ខេត្ត | ចំនួនរួម | ស្រី | អនីតិជន | ស្រី |
| --- | --- | --- | --- | --- | --- |
| ១ | បន្ទាយមានជ័យ | ៨៩៩ | ២៧៨ | | |
| ២ | បាត់ដំបង | ១៣ | ៣ | | |
| ៣ | ស្វាយរៀង | ៤ | ៣ | ០២ | ០១ |
| ៤ | កោះកុង | ២១ | ៧ | | |
| | សរុប | ៩៣៧ នាក់ | ២៩១ នាក់ | ០២ នាក់ | ០១ នាក់ |

➕ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មណ្ឌលទទួលពលករកំរៀង៖ បានទទួលពលករ សរុបចំនួន ៣៣នាក់ (ស្រី ០៨នាក់)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ១៨ករណី (ប្រៀបធៀបខែកុម្ភៈ មានចំនួន ១៥ករណី កើនឡើង ០៣ករណី) ស្មើនឹង ២០% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ចំនួន **២៨នាក់** (ស្រី០៥នាក់) ជនជាតិចិន ០១នាក់។
- សង្គ្រោះជនរងគ្រោះចំនួន **៦២នាក់** មានអាយុក្រោម១៥ឆ្នាំ **១៥នាក់** អាយុ១៥-១៧ឆ្នាំ ២០នាក់ និង អាយុ១៨ឆ្នាំឡើង ២៧នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៩នាក់ អន្តោប្រវេសន៍ ៣០នាក់ គ្រួសារ១៣ នាក់)។ ក្នុងនោះចែកជា៖

➕ **<u>ករណីអំពើជួញដូរមនុស្ស</u>**

បង្ក្រាបបាន ០៨/០៣ករណី (កើនឡើង ០៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១៣នាក់** (ស្រី០២នាក់) ជនជាតិចិន ០១នាក់។ សង្គ្រោះជនរងគ្រោះ ៣២នាក់ មានអាយុក្រោម១៥ឆ្នាំ ០៣នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុ១៨ឆ្នាំឡើង ២៦នាក់ (បញ្ជូនទៅអន្តោប្រវេសន៍ ៣០នាក់ គ្រួសារ ០២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០២ | | ០១ |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០១ | ចិន១ | ២២ |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ០២ | ០៦ | | ០១ |
| -អំពើនាំឆ្លងដែន | ០១ | ០១ | | ០១ |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០៣ | ០៣ | | ០៧ |
| សរុប | ០៨ ករណី | ១៣ នាក់ | ០១ នាក់ | ៣២ នាក់ |

➕ **<u>ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ</u>**

បង្ក្រាបបាន ១០/១២ករណី (ថយចុះ ០២ករណី) ឃាត់ខ្លួនជនសង្ស័យ ១៥នាក់ (ស្រី០៣នាក់)។ សង្គ្រោះជនរងគ្រោះ ៣០នាក់ មានអាយុក្រោម១៥ឆ្នាំ ១២នាក់ អាយុ១៥-១៧ឆ្នាំ ១៧នាក់ និងអាយុ១៨ឆ្នាំឡើង ០១នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ១៩នាក់ គ្រួសារ ១១នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០២ | ១៩ |
| -រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | ០១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០២ | ០៥ | ០៣ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៥ | ០៥ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ | ០២ |
| សរុប | ១០ ករណី | ១៥ នាក់ | ៣០ នាក់ |

## ឃ. កិច្ចការពារជនរងគ្រោះ

### ឃ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងប្រទេស និងក្រៅប្រទេស សរុបចំនួន ១៥នាក់(ស្រី)។ ក្រោយពីបានកំណត់អត្តសញ្ញាណដោយមន្ត្រីនគរបាលយុត្តិធម៌ បានរកឃើញជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ១៤នាក់ (ប្រុស ០៤នាក់ៈ អនីតិជន ០២នាក់)ក្នុងនោះមានៈ

- ជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះ មកពីក្រៅប្រទេសចំនួន ១៤នាក់(ស្រី) មកពីប្រទេសចិន ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ០៩នាក់ និងមកពីប្រទេសថៃ ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ០៤នាក់ និងសង្ស័យថារងគ្រោះ ០១នាក់។
- ជនរងគ្រោះក្នុងប្រទេស ជាជនជាតិបរទេសចំនួន ០១នាក់(ស្រី) ជនជាតិចិន ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម។

### ឃ.២. ការស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការដៃគូ សរុបចំនួន ១០នាក់(ស្រី)៖ បានបញ្ជូនទៅទទួលសេវាពីអង្គការមានដូចជាៈ អង្គការការីតាសកម្ពុជា ០១នាក់(ស្រី) អង្គការមូលនិធិហាការអន្តរជាតិ ០២នាក់(ស្រី) អង្គការរតនៈ ០៤នាក់(ស្រី) អង្គការសម្ព័ន្ធចាប់ដៃ ០១នាក់(ស្រី) អង្គការអាដហុក ០២នាក់(ស្រី) និងស្នាក់នៅក្នុងមជ្ឈមណ្ឌលស្តារនីតិសម្បទា ០៣នាក់(ប្រុស)។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះ

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប ០២នាក់(ស្រី ០១នាក់)។

### ឃ.៤. មាតុភូមិនិវត្តន៍

បានធ្វើមាតុភូមិនិវត្តន៍ជនបរទេសទៅប្រទេសដើមវិញ សរុបចំនួន ០១នាក់(ស្រី) ជនជាតិចិន។

# III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការមេត្រីអន្តរជាតិ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការដល់មន្ត្រីជំនាញនាយកដ្ឋាន។ | ០១ | ២០ | ០២ |
| ២ | ខេត្តបន្ទាយមានជ័យៈ មន្ទីរកិច្ចការនារីខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស។ | ០១ | ២១ | ១៨ |
| | សរុប | ០២លើក | ៤១នាក់ | ២០នាក់ |

### ក.២. សិក្ខាសាលា

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយគម្រោងJICA បានរៀបចំសិក្ខាសាលាចំនួន ០២វគ្គ៖ ១-ស្តីពីការធ្វើបច្ចុប្បន្នភាព «បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល គម្រោងអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ជនរងគ្រោះដែលរួចពីការជួញដូរមនុស្ស» នៅសណ្ឋាគារ HIMAWARI ភ្នំពេញ មានអ្នកចូលរួមចំនួន ៤៨នាក់ (ស្រី ២៨នាក់)។ ២-ស្តីពីការពិនិត្យលើខ្លឹមសារចុងក្រោយនៃការកែសម្រួលពីការធ្វើបច្ចុប្បន្នភាពលើ «គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប» នៅសណ្ឋាគារ SUM&MOON ភ្នំពេញ មានអ្នកចូលរួមចំនួន ៦១នាក់(ស្រី២៣នាក់)។ សិក្ខាសាលាទាំងពីរវគ្គនេះប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ ការរៀបចំកិច្ចប្រជុំក្នុងប្រទេស

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំចំនួន ០៤លើក អ្នកចូលរួមចំនួន ៨១នាក់ (ស្រី ២៥នាក់)៖

- កិច្ចប្រជុំកម្រិតបច្ចេកទេស ជាមួយក្រសួង ស្ថាប័ន ដែលជាអនុប្រធាន គ.ជ.ប.ជ ដើម្បីពិនិត្យរបាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ អ្នកចូលរួមចំនួន ៣២នាក់ (ស្រី ១២នាក់) នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ

- កិច្ចប្រជុំជាមួយអង្គការដៃគូ ពិនិត្យរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០២៥ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងត្រៀមរៀបចំកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ អ្នកចូលរួម ១២នាក់ (ស្រី ០៤នាក់) នៅសាលប្រជុំ គ.ជ.ប.ជ

- កិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិនិត្យ និងពង្រឹងការអនុវត្តការងារ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែកុម្ភៈ អ្នកចូលរួមចំនួន ២៥នាក់ (ស្រី ០៧នាក់)

- កិច្ចប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យ និងតាមដានការអនុវត្តកាងារ ស្តីពីការត្រៀមរៀបចំពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ១២នាក់ (ស្រី ០២នាក់)។

❖ ការចូលរួមកិច្ចប្រជុំក្នុងប្រទេស និងនៅក្រៅប្រទេស

▪ ខេត្តកណ្តាល លោកជំទាវ អភិបាល នៃគណៈអភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានអញ្ជើញទៅចូលរួមសន្និបាត ផ្លាស់ប្តូរចែករំលែកបទពិសោធន៍ រវាងស្ត្រីធុរកិច្ចបីខេត្ត ខេត្តកណ្តាល ខេត្តតាកែវ (ព្រះរាជាណាចក្រកម្ពុជា) និងខេត្តអានយ៉ាង(ប្រទេសវៀតណាម) ស្តីពីច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការប្រើអំពើហិង្សាក្នុងគ្រួសារ ការកេងប្រវ័ញ្ចន៍កម្លាំងពលកម្មលើកុមារ និងការប្រើប្រាស់គ្រឿងញៀន នៅប្រទេសវៀតណាម។

### ខ.២. ជំនួបពិភាក្សាការងារ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និងថ្នាក់ដឹកនាំ ក្រុមការងារនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានទទួលជំនួបពិភាក្សាការងារ ជាលក្ខណៈអន្តរជាតិ ជាមួយប្រតិភូ បណ្តាស្ថានទូត អង្គការជាតិ អន្តរជាតិ និងជំនួបកម្រិតផ្ទៃក្នុងជាតិ បានចំនួន ០៧លើក រួមមាន៖

១.ឯកឧត្តម ងួន រតនៈ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ស្តីពីគម្រោងការងារដឹកនាំចុះតាមដាន ត្រួតពិនិត្យ ការអនុវត្តការងាររបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃខេត្តជាប់ព្រំដែនថៃ

២.ប្រតិភូក្រសួងការបរទេសអូស្ត្រាលី ដឹកនាំដោយ លោកស្រី Lynn Bell ជា Australian Ambassador to Counter Modern Slavery អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៣.តំណាងស្ថានទូតសឹង្ហបុរី ស្តីពីបញ្ហាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

៤.លោកស្រី Sonja Loosli នាយិកាប្រចាំកម្ពុជា នៃអង្គការការីតាសស្វីស ដើម្បីស្វែងយល់បន្ថែមអំពីស្ថានភាព ទេសន្តរប្រវេសន៍នៅកម្ពុជា

៥.ក្រុមអង្គការមិនមែនរដ្ឋាភិបាល មានជាអាទិ៍ អង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិ អង្គការ IJM និងអង្គការ IOM ដើម្បីពិភាក្សាលើកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស គឺ ៤០លើក មានអ្នកចូលរួមសរុប ៤២៨នាក់(ស្រី ២០៣នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **២៣**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **១៧**លើក។ (ឧបសម្ព័ន្ធ)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើ វិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់ នាំឱ្យធកល្វែង ។
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

**គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ**

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយធាប់ហើស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្តាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់វ័យពីដំណាក់កាលដំបូង ដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់ មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋាន ទទួលបន្ទុក ការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្តុះបណ្តាលតាមជំនាញសម្រាប់ការអនុវត្តការងារឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងកិច្ចប្រជុំគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅខែមេសា ឆ្នាំ ២០២៥

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្តែកលើយុទ្ធសាស្រ្តរួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែក ការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំង និយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៣. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៤. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹង ជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេស ស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៥. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តា ក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដាន ការអនុវត្ត

៦. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៧. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យ យុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៨. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល

៩. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពី ប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយ ចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះ អាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយ នៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ ចន្ទ ១រោច ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២៥

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ
**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**
-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
**"ដើម្បីជូនជ្រាប"**
-ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៤០លើក) មនុស្សចំនួន ៤២៨នាក់ (ស្រី ២០៣នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>-វេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។<br>-ពិធីអបអរសាទរ ទិវាអន្តរជាតិនារី ខួបលើកទី១១៤ ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ កែ សួនសុភី ស សុខា នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-កិច្ចប្រជុំ រដ្ឋបាលខេត្តជាប់ព្រំដែនប្រទេសវៀតណាម ថៃ និងឡាវ ស្តីពីការងារសន្តិសុខតាមព្រំដែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-ពិធីអបអរសាទរ ទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៤ ឆ្នាំ២០២៥ ក្រោមប្រធានបទ សិទ្ធិ សមភាព និងភាពអង់អាចចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយខេត្តកំពង់ឆ្នាំង នៅខេត្តកំពង់ឆ្នាំង។<br>-ពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជានារីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីអបអរសាទរទិវាអន្តរជាតិនារី ខួបលើកទី១១៤ ឆ្នាំ២០២៥។<br>-កិច្ចប្រជុំផ្សព្វផ្សាយព្រឹត្តិការណ៍ និងគោលការណ៍សំខាន់ៗ ដោយសង្ខេបប្រចាំសប្តាហ៍របស់អគ្គនាយកដ្ឋានរដ្ឋបាល នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-ពិធីបើកសិក្ខាសាលា ស្តីពីការថែទាំដែលយល់ដឹងពីការប៉ះទង្គិចផ្លូវចិត្ត ដល់កុមាររងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។<br>-ចុះសួរសុខទុក្ខ សំណេះសំណាល និងនាំយកនូវសម្ភារៈប្រើប្រាស់ ថវិកាចែកជូនដល់កងកម្លាំងឈរជើងនៅប្រាសាទតាមាន់ កងពលតូចថ្មើរជើងលេខ៤២យោធភូមិភាគទី៤ និងវរសេនាតូចនគរបាលការពារព្រំដែនគោក៧០២។<br>-ជាអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយគម្រោង និងកិច្ចប្រជុំត្រីមាសទី១ របស់គម្រោងសុវត្ថិភាពទេសន្តរប្រវេសន៍នៅកម្ពុជា ជំហានទី២ នៅខេត្តបាត់ដំបង។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម<br>-សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងពិធីផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១០ ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការផ្សព្វផ្សាយ និងតាមដានបន្តអនុសាសន៍ ដែលទទួលបានពីការពិនិត្យជាសាកលតាមកាលកំណត់ ជុំទី៤ ក្រោមអធិបតីភាព ឯកឧត្តម កែវ រ៉េមី ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នៅសណ្ឋាគារណូវ៉ូថេល។ |

- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

-លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (២៥ច្បាប់) លិខិតចូល (១២ច្បាប់)

-លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(៤៦ច្បាប់)លិខិតចូល(២៩ច្បាប់)

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

-ប្រជុំក្នុងក្រុម ដើម្បីពិនិត្យ និងកែសម្រួលផែនការសកម្មភាព សម្រាប់អនុវត្តឆ្នាំ២០២៥ របស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់។

-ប្រជុំកម្រិតបច្ចេកទេស ជាមួយតំណាងអន្តរក្រសួង ស្ថាប័ន ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ឆ្នាំ២០២៤ របស់ គ.ជ.ប.ជ។

-ប្រជុំពិនិត្យសម្រេចលើផែនការសកម្មភាព សម្រាប់អនុវត្តឆ្នាំ២០២៥ របស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់។

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

-ចូលរួមកិច្ចប្រជុំ ស្តីពីគោលនយោបាយជាតិ សុខភាពជនទេសន្តរប្រវេសន៍ លើសកម្មភាពការងារកែលម្អបញ្ហាប្រឈមនានា ដែលជាឧបសគ្គ និងលើកទិសដៅអនុវត្តន៍បន្ត ក្រោមអធិបតីភាព ឯកឧត្តម **ម៉ៅ ចាន់អ៊ារ៉** អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល នៅសាលប្រជុំ ក្រសួងសុខាភិបាល។

-ចូលរួមសិក្សាស្រាវជ្រាវពីស្ថានភាពពលករនេសាទនៅខេត្តព្រះសីហនុ នៅសាលប្រជុំរដ្ឋបាលខេត្តព្រះសីហនុ។

-ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានដឹកនាំលោកប្រធាន និងអនុប្រធានក្រុមជំនួយកិច្ចកា ចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យ និងរៀបចំផែនការសកម្មភាព សម្រាប់អនុវត្ត ឆ្នាំ២០២៥ របស់ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ក្រោមការដឹកនាំរបស់ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។

-ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក និងជាប្រធានក្រុមការងារព័ត៌មានវិទ្យា រូបភាពបទយកការណ៍ និងផ្សព្វផ្សាយ បានដឹកនាំអនុប្រធាន និងសមាជិក ប្រជុំត្រៀមរៀបចំផ្សព្វផ្សាយរបាយការណ៍ជាតិ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤ និងលើកទិសដៅឆ្នាំ២០២៥ នៅសាលប្រជុំ គ.ជ.ប.ជ។

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយអនុសាសន៍លើកទី១៧ នៃវេទិកាអាស៊ាន ស្តីពីទេសន្តរប្រវេសន៍ការងារ ក្រោមប្រធានបទ "ការថែទាំ និងទេសន្តរប្រវេសន៍ការងារ ថែទាំ និងទេសន្តរប្រវេសន៍ការងារក្នុងតំបន់អាស៊ាន" នៅសណ្ឋាគារសាន់វេ។

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូល លើការរៀបចំឯកសារណែនាំតម្រង់ទិសមុនចេញដំណើរទៅធ្វើការនៅប្រទេសថៃ នៅសណ្ឋាគារហើម៉ាវ៉ារី។

- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**

-ចូលរួមកិច្ចប្រជុំ ត្រួតពិនិត្យវឌ្ឍនភាពការងារ និងទិសដៅបន្តដែលត្រូវអនុវត្ត របស់ក្រុមការងារពិធីការ និងបដិសណ្ឋារកិច្ច (ក្រុមទីការងារទី៣) ស្តីពីការរៀបចំពិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤ និងលើកទិសដៅឆ្នាំ២០២៥ ក្រោមអធិបតីភាព លោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង នៅសាលប្រជុំ គ.ជ.ប.ជ។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

| | |
|---|---|
| | -ចូលរួមកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រុមការងារ SOMTC-កម្ពុជា ស្តីពីការប្រមូលធាតុចូលលើឯកសារ ស្តីពីបន្ទាត់សកម្មភាពយុទ្ធសាស្ត្រសម្រាប់អនុវត្តក្នុងផែនការយុទ្ធសាស្ត្រចក្ខុវិស័យអាស៊ានឆ្នាំ២០៤៥ ក្រោមសសរស្តម្ភសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ដឹកនាំដោយ ឯកឧត្តម ប៉ោ កក្កិ រដ្ឋលេខាធិការ និងជាប្រធាន SOMTC-កម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ។<br>-ដឹកនាំកិច្ចប្រជុំ ស្តីពីការប្រមូលទិន្នន័យ រួមមានឯកសារ និងរូបភាពផ្សេងៗ ដែលទាក់ទងនឹងកម្មវិធីផ្សព្វផ្សាយរបាយការណ៍ជាតិ ឆ្នាំ២០២៤ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធវីគី ដើម្បីរក្សាទុកជាឯកសារប្រើប្រាស់បន្ត។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៧លើក អ្នកចូលរួមសរុបចំនួន ៤២៨នាក់ (ស្រី ២០៣នាក់)** | |
| ខេត្តសៀមរាប | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំត្រីមាសទី១ ចំនួន០១លើក អ្នកចូលរួមចំនួន៥០នាក់ ស្រី៣២នាក់។<br>-ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំ ចំនួន១២លើក អ្នកចូលរួមចំនួន៣២២នាក់ ស្រី១៣៩នាក់។ |
| ខេត្តកណ្តាល | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែមីនា ចំនួន០២លើក អ្នកចូលរួមចំនួន៣៥នាក់ ស្រី២៤នាក់។ |
| ខេត្តកំពង់ចាម | -លេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ ចំនួន០១លើក។ |
| ខេត្តឧត្តរមានជ័យ | -លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំមីនា ចំនួន០១លើក អ្នកចូលរួមចំនន្ទួន២១នាក់ ស្រី ០៨នាក់។ |